លេខ៖ ០២២.០២
ចេញផ្សាយថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២

## កម្មវិធីចែករំលែក
## ចំណេះដឹងធានារ៉ាប់រង

និយ័តករធានារ៉ាប់រងកម្ពុជា

# ការធានារ៉ាប់រង៖ អ្វីដែលគួរយល់ដឹង



**ការធានារ៉ាប់រង៖** គឺជាការធ្វើ កិច្ចសន្យាធានារ៉ាប់រង ដែលក្នុងនោះអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ បុព្វលាភធានារ៉ាប់រង ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រង ត្រូវធ្វើសំណង ដល់ការខូចខាត ការបាត់បង់ ទ្រព្យសម្បត្តិដែលបង្កឡើង ដោយហេតុការណ៍គ្រោះថ្នាក់ ឬនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺ ឬនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រង ស្ថិតក្នុង លក្ខខណ្ឌកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង។

**កិច្ចសន្យាធានារ៉ាប់រង៖** សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះក្រុមហ៊ុនធានារ៉ាប់រង ព្រមទទួលនូវហានិភ័យជាក់លាក់ណាមួយ ដោយទទួលមកវិញនូវការបង់ បុព្វលាភធានារ៉ាប់រង ពីអ្នកត្រូវបានធានារ៉ាប់រង។

**បុព្វលាភធានារ៉ាប់រង៖** ជាទឹកប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង តាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងក្នុងបណ្ណសន្យារ៉ាប់រង។

www.irc.gov.kh
Insurance Regulator of Cambodia
rtc@irc.gov.kh

រៀបចំដោយ **កញ្ញា ឡាយ សុនិមល**
មន្ត្រីការិយាល័យបណ្តុះបណ្តាល
នៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល
និងសហប្រតិបត្តិការ

